# វគ្គសិក្សា
# បច្ចេកវិទ្យាទំនាក់ទំនង
# និងបញ្ញាសិប្បនិម្មិតសម្រាប់ការអប់រំ

វគ្គសិក្សានៅលើ ថ្នាលអភិវឌ្ឍសមត្ថភាព - CDP

## ១.ការពិពណ៌នាអំពីវគ្គសិក្សា

វគ្គសិក្សានេះត្រូវបានរៀបចំឡើងជាពិសេសសម្រាប់គ្រូបង្រៀននៅកម្ពុជា ក្នុងគោលបំណងពង្រឹងសមត្ថភាពអ្នកសិក្សានូវចំណេះដឹង និងជំនាញជាក់ស្តែងក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងឌីជីថល និងបញ្ញាសិប្បនិម្មិត (AI) ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀននិងរៀននៅក្នុងបរិបទបច្ចេកវិទ្យាឌីជីថល។ វគ្គសិក្សានេះនឹងជួយអ្នកឱ្យសម្របខ្លួនទៅនឹងបរិយាកាសអប់រំឌីជីថលដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័សប្រកបដោយប្រសិទ្ធភាព។

នៅក្នុងបរិបទអប់រំការចូលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលកំពុងកើនឡើង វគ្គសិក្សានេះនឹងផ្តល់ឱ្យអ្នកនូវឧបករណ៍ចាំបាច់ដើម្បីបង្កើនការចូលរួមរបស់សិស្ស កែលម្អការសហការ និងធ្វើឱ្យការអប់រំកាន់តែមានភាពងាយស្រួល ដែលនឹងផ្តោតលើការដោះស្រាយបញ្ហាប្រឈមជាក់លាក់របស់គ្រូបង្រៀន ដូចជាការទំនាក់ទំនងមានកម្រិត និងធនធានមានកម្រិត ហើយនឹងផ្តល់នូវដំណោះស្រាយជាក់ស្តែង និងប្រកបដោយភាពច្នៃប្រឌិត។

តាមរយៈវគ្គសិក្សានេះ អ្នកនឹងរៀនពីរបៀបប្រើប្រាស់វេទិកាទំនាក់ទំនងឌីជីថលផ្សេងៗ ការពារសុវត្ថិភាព និងឯកជនភាពតាមអ៊ីនធឺណិត និងបញ្ចូលឧបករណ៍ បញ្ញាសិប្បនិម្មិត- AI ទៅក្នុងវិធីសាស្ត្របង្រៀនរបស់អ្នក។ វគ្គសិក្សានេះនឹងជួយអ្នកក្នុងការអភិវឌ្ឍផែនការមេរៀនប្រកបដោយភាពច្នៃប្រឌិត បង្កើតបទពិសោធន៍សិក្សាអន្តរកម្ម និងវាយតម្លៃចំណេះដឹងរបស់សិស្សកាន់តែមានប្រសិទ្ធភាព។

ជាចុងក្រោយ វគ្គសិក្សានេះនឹងផ្តល់ចំណេះដឹងយ៉ាងទូលំទូលាយដល់អ្នកឱ្យមានការផ្លាស់ប្តូរឌីជីថល និងបង្កើតអនាគតកាន់តែប្រសើរសម្រាប់សិស្សានុសិស្សកម្ពុជា។

## គោលបំណងនៃវគ្គសិក្សា

បន្ទាប់ពីបញ្ចប់វគ្គសិក្សានេះ អ្នកចូលរួមនឹងអាច៖

- យល់ដឹងអំពីគោលការណ៍គ្រឹះនៃបច្ចេកវិទ្យាទំនាក់ទំនងឌីជីថល និង បញ្ញាសិប្បនិម្មិត AI ក្នុងការអប់រំ។
- ប្រើប្រាស់ឧបករណ៍ឌីជីថលផ្សេងៗ ដើម្បីកែលម្អការបង្រៀន និងរៀនសូត្រ។
- ការអនុវត្តសម្រាប់សុវត្ថិភាព និងឯកជនភាពតាមអ៊ីនធឺណិត។
- រួមបញ្ចូលឧបករណ៍ AI ទៅក្នុងផែនការមេរៀន និងសកម្មភាពក្នុងថ្នាក់រៀន។
- វាយតម្លៃការអនុវត្ត និងប្រសិទ្ធភាពនៃបច្ចេកវិទ្យាឌីជីថលក្នុងការអប់រំ។

## ម៉ូឌុល១: មូលដ្ឋានគ្រឹះនៃទំនាក់ទំនងឌីជីថល

ម៉ូឌុលនេះ នឹងផ្តល់ឱ្យអ្នកនូវចំណេះដឹង និងជំនាញគ្រឹះអំពីរបៀបទំនាក់ទំនងឌីជីថលប្រកបដោយប្រសិទ្ធភាព និងបច្ចេកទេសនៃការងារសហការគ្នាដើម្បីសម្រេចបានគោលដៅរួម។

គោលបំណង: បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ អ្នកនឹងអាចយល់ដឹងអំពីសារៈសំខាន់ វិធីសាស្ត្រទំនាក់ទំនងឌីជីថលប្រកបដោយប្រសិទ្ធភាព និងពង្រឹងជំនាញក្នុងការធ្វើការងារសហការគ្នាជាក្រុម ដោយប្រើប្រាស់ឧបករណ៍ឌីជីថលសមស្រប ដើម្បីសម្រេចបាននូវផលិតភាពការងារខ្ពស់ និងជោគជ័យរួម។

មេរៀនទី១: ទំនាក់ទំនងឌីជីថល

សេចក្តីណែនាំ: នៅក្នុងយុគសម័យសាកលភាវូបនីយកម្ម និងបដិវត្តន៍ឧស្សាហកម្ម ៤.០ ការទំនាក់ទំនងបានប្តូរទៅជាទម្រង់ឌីជីថល ដែលជាឆ្អឹងខ្នងនៃអាជីវកម្ម ការអប់រំ និងសង្គមបច្ចុប្បន្ន។ បច្ចេកវិទ្យាបានធ្វើឱ្យការផ្លាស់ប្តូរព័ត៌មានលឿនរហ័ស និងបង្រួមចម្ងាយ។ ហេតុនេះ ការប្រើប្រាស់ទំនាក់ទំនងឌីជីថលប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាពគឺជាជំនាញសំខាន់បំផុតសម្រាប់បុគ្គល និងស្ថាប័ន។

គោលបំណង: បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកនឹងអាច:

- កំណត់និយមន័យនៃការទំនាក់ទំនងឌីជីថល និងយល់ពីវិវឌ្ឍន៍ទំនាក់ទំនងឌីជីថល។
- បែងចែកភាពខុសគ្នារវាងការទំនាក់ទំនងបែបប្រពៃណី និងបែបឌីជីថល ព្រមទាំងវិភាគពីផលប៉ះពាល់នៃការផ្លាស់ប្តូរនេះទៅលើប្រសិទ្ធភាពការងារ និងការសម្រេចចិត្ត។
- កំណត់អត្តសញ្ញាណ ជ្រើសរើស និងប្រើប្រាស់ឧបករណ៍ឌីជីថលសំខាន់ៗសម្រាប់បំពេញតម្រូវការវិជ្ជាជីវៈ ដោយដឹងពីគុណសម្បត្តិ ដែនកំណត់ និងហានិភ័យរបស់វា។

**មេរៀនទី២: ការងារសហការគ្នា**

សេចក្តីណែនាំ: ការងារសហការ (Collaborative Work) គឺជាវិធីសាស្ត្រចាំបាច់ក្នុងយុគសម័យបច្ចេកវិទ្យា ដែលទាមទារឱ្យមនុស្សធ្វើការរួមគ្នាដើម្បីដោះស្រាយបញ្ហា និងសម្រេចបានលទ្ធផលរួម។ ខ្លឹមសារនេះផ្តោតលើការបណ្តុះបណ្តាលសមត្ថភាពសិក្ខាកាមឱ្យចេះសហការ ប្រាស្រ័យទាក់ទងដោយប្រសិទ្ធភាព និងប្រើប្រាស់ឧបករណ៍ឌីជីថលដូចជា Google Workspace ដើម្បីធានាបាននូវការងារជាក្រុមប្រកបដោយជោគជ័យ និងគុណភាពខ្ពស់។

គោលបំណង: បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកនឹងអាច:

- សហការ និងទំនាក់ទំនង ប្រកបដោយប្រសិទ្ធភាព។
- ប្រើប្រាស់ ឧបករណ៍ឌីជីថលសម្រាប់ធ្វើការងាររួមគ្នា ការប្រើប្រាស់ Google Workspace ។
- ដោះស្រាយបញ្ហា ក្នុងការងាររួមគ្នា និងទទួលខុសត្រូវ លើតួនាទីរៀងៗខ្លួន។

## ម៉ូឌុល២: សុវត្ថិភាព និងឯកជនភាពឌីជីថល

សេចក្តីណែនាំ: ម៉ូឌុលនេះនឹងបង្រៀនអ្នកអំពីសារៈសំខាន់នៃសុវត្ថិភាព និងឯកជនភាពឌីជីថល ដោយផ្តោតលើរបៀបការពារខ្លួនអ្នក និងសិស្សពីហានិភ័យ និងការគំរាមកំហែងតាមអ៊ីនធឺណិត ដូចជា ការបាត់បង់ពាក្យសម្ងាត់ ការចែករំលែកឯកសារដោយគ្មានសុវត្ថិភាព និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដោយក្រមសីលធម៌។

គោលបំណង: បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ អ្នកនឹងយល់ដឹងពីហានិភ័យឌីជីថល ការពារគណនីដោយពាក្យសម្ងាត់ និងដាក់ពាក្យសម្ងាត់២ជាន់ (Two Factor Authentication-2FA) ប្រើប្រាស់ cloud ដោយសុវត្ថិភាព ចេះកំណត់សិទ្ធិឯកសារដោយត្រឹមត្រូវ និងអាចទប់ស្កាត់ហានិភ័យនានា ពេលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

**មេរៀនទី១: ការការពារគណនីដោយពាក្យសម្ងាត់ និងសុវត្ថិភាព**

សេចក្តីណែនាំ: មេរៀននេះនឹងគ្របដណ្តប់លើការបង្កើតពាក្យសម្ងាត់រឹងមាំ និងការដាក់លេខកូដសម្ងាត់២ជាន់សម្រាប់គណនី Gmail និងតេឡេក្រាម (Telegram) ដើម្បីធានាសុវត្ថិភាពព័ត៌មាន និងការបង្រៀនប្រកបដោយក្រមសីលធម៌។

គោលបំណង: បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកនឹងអាច:

- ពង្រឹងសមត្ថភាពរបស់លោកគ្រូ អ្នកគ្រូក្នុងការការពារគណនីអ៊ីនធឺណិត
- បង្កើនការយល់ដឹង និងជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដោយសុវត្ថិភាព
- បង្កើតពាក្យសម្ងាត់រឹងមាំសម្រាប់គណនី Gmail និងតេឡេក្រាម (Telegram)
- រៀនអំពីការដាក់លេខកូដសម្ងាត់២ជាន់ ដើម្បីធានាសុវត្ថិភាពព័ត៌មាន
- ធានាថាការបង្រៀន និងការងារប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយក្រមសីលធម៌ និងប្រសិទ្ធភាព។

**មេរៀនទី២: ការចែករំលែកឯកសារដោយសុវត្ថិភាព** - Cloud Storage, Safe Sharing

សេចក្តីណែនាំ: មេរៀននេះនឹងបង្រៀនអ្នកពីរបៀបចែករំលែកឯកសារដោយសុវត្ថិភាពលើអ៊ីនធឺណិតដោយប្រើប្រាស់ការផ្ទុកទិន្នន័យលើពពក (Cloud storage) និងមានការទទួលខុសត្រូវខ្ពស់ស្របតាមគោលការណ៍សុវត្ថិភាពគ្រប់គ្រងការចូលប្រើ។

គោលបំណង: បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកនឹងអាច:

- ប្រើប្រាស់ cloud storage ដើម្បីរក្សាទុក និងចែករំលែកឯកសារ។
- កំណត់សិទ្ធិអនុញ្ញាតត្រឹមត្រូវសម្រាប់ប្រើប្រាស់ឯកសារដែលបានចែករំលែក។
- យល់ដឹងអំពីហានិភ័យ និងជៀសវាងការចែករំលែកឯកសារដោយមិនមានសុវត្ថិភាព។

## ម៉ូឌុលទី៣:បញ្ញាសិប្បនិម្មិត សម្រាប់បង្រៀន និងរៀន

ម៉ូឌុលនេះ ត្រូវបានរចនាឡើងដើម្បីផ្តល់នូវការយល់ដឹងអំពីវិធីដែលបញ្ញាសិប្បនិម្មិត (AI) អាចជួយកែប្រែការបង្រៀន និងការរៀនសូត្រដោយផ្តោតលើគោលគំនិតមូលដ្ឋាន និងការអនុវត្តជាក់ស្តែង។ ជាផ្នែកមួយនៃការត្រៀមខ្លួនសម្រាប់អនាគតនៃការអប់រំ អ្នកចូលរួមនឹងបានស្វែងយល់ពីឧបករណ៍ AI ផ្សេងៗដែលអាចជួយពង្រឹងបទពិសោធន៍របស់គ្រូបង្រៀន និងសិស្ស។ តាមរយៈម៉ូឌុលនេះ អ្នកនឹងរៀនពីវិធីរួមបញ្ចូល AI នៅក្នុងផែនការមេរៀន ដើម្បីធានាថាការសិក្សា និងការបង្រៀនមានប្រសិទ្ធភាព និងដំណើរការបានល្អប្រសើរឡើង។

បន្ទាប់ពីបញ្ចប់ម៉ូឌុលនេះ អ្នកនឹងអាច:

- យល់ដឹងអំពីមូលដ្ឋានគ្រឹះនៃ AI និងសក្តានុពលរបស់វាក្នុងការចូលរួមក្នុងការអប់រំ។
- បញ្ជាក់ឧបករណ៍ AI ដែលអាចធ្វើឱ្យការបង្រៀន និងការរៀនសូត្រកាន់តែងាយស្រួល និងមានប្រសិទ្ធភាព។
- រួមបញ្ចូល AI ទៅក្នុងការបង្រៀនដោយប្រើផែនការមេរៀនដែលបានរៀបចំប្រកបដោយច្នៃប្រឌិត និងមានចីរភាព។

**មេរៀនទី១: សេចក្តីណែនាំអំពី បញ្ញាសិប្បនិម្មិត** - AI

សេចក្តីណែនាំ: មេរៀននេះនឹងផ្តល់នូវទិដ្ឋភាពទូទៅនៃ AI រួមទាំងគោលគំនិតសំខាន់ៗ និងឧទាហរណ៍នៃការអនុវត្ត AI នៅក្នុងឧស្សាហកម្មផ្សេងៗ។

គោលបំណង: បន្ទាប់ពីបញ្ចប់មេរៀននេះ អ្នកនឹងអាច:

- កំណត់និយមន័យ AI និងពន្យល់គោលគំនិតសំខាន់ៗ។
- រៀបរាប់អំពីការអនុវត្ត AI នៅក្នុងវិស័យផ្សេងៗ។
- យល់ដឹងអំពីសក្តានុពល និងដែនកំណត់របស់ AI។

**មេរៀនទី២៖ បញ្ញាសិប្បនិម្មិតសម្រាប់បង្រៀន និងរៀន**

មេរៀននេះផ្តល់នូវចំណេះ និងសមត្ថភាពការគិត វិភាគ ការរៀនសូត្រ និងដោះស្រាយបញ្ហា ដោយប្រើប្រាស់បញ្ញាសិប្បនិម្មិត និង ឧបករណ៍ដ៏សំខាន់ ក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការបង្រៀន និងការរៀន។ ការយល់ដឹងអំពីគោលគំនិត និងការអនុវត្តជាក់ស្តែងនៃ AI នៅក្នុងថ្នាក់រៀន សម្រាប់គ្រូបង្រៀន និងសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដើម្បីត្រៀមខ្លួនសម្រាប់យុគសម័យឌីជីថល។

គោលបំណង: បន្ទាប់ពិបញ្ចប់មេរៀននេះ អ្នកនិងអាចៈ

- យល់ដឹង អំពីនិយមន័យ ទម្រង់ផ្សេងៗ និងចំណេះដឹងនៃការអនុវត្ត AI នៅក្នុងបង្រៀន និងរៀន។
- កំណត់អត្តសញ្ញាណ និង អនុវត្ត ឧបករណ៍ AI សំខាន់ៗដែលសមស្របសម្រាប់កិច្ចការបង្រៀន និងការរៀន។
- មានជំនាញ និងបញ្ចូល ពាក្យបញ្ជា (Prompts) ប្រកបដោយប្រសិទ្ធភាព ដើម្បីទាញយកលទ្ធផលត្រឹមត្រូវ និងមានប្រយោជន៍ពីម៉ូដែល AI ។
- ប្រើប្រាស់ ឧបករណ៍ AI ជាក់ស្តែង ដើម្បីជួយសម្រួលដល់ដំណើរការបង្រៀន (ការរៀបចំផែនការមេរៀន ការងាររដ្ឋបាល) និងដំណើរការសិក្សា (ការរៀនផ្ទាល់ខ្លួន ការស្រាវជ្រាវ ការផ្តល់មតិត្រឡប់)។